# យើងទាំងអស់គ្នាត្រូវបានរើសឲ្យធ្វើជាទ័ព

*ដោយអែលឌើរ ដែប្រ៊ី អ័រ ហ្វឡិន*
*នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

បងប្អូនប្រុស ក្នុងវិញ្ញាណនៃភាពជាបងប្អូនប្រុសរបស់យើង នារាត្រីនេះខ្ញុំចង់និយាយដោយបើកចំហរ ។ ខ្ញុំក៏បូកបញ្ចូលយុវជននៃបព្វជិតភាពអើរ៉ុនក្នុងការបើកចំហរនោះដែរ ។

ពេលយើងនិយាយពីភាពអស្ចារ្យនៃការនិមិត្តរបស់យ៉ូសែប ស្ម៊ីធ ពេលខ្លះយើងនិយាយតែបន្តិចបន្តួចប៉ុណ្ណោះពីជម្លោះដ៏កាចសាហាវដែលបានកើតឡើងពីមុនហេតុការណ៍ ជាជម្លោះមួយដែលមានគោលបំណងដើម្បីបំផ្លាញក្មេងប្រុសនោះ បើអាចធ្វើទៅបាន តែបើមិនអាចធ្វើបាន វានឹងបង្វាំងដល់វិវរណៈដែលត្រូវកើតមាន ។ យើងមិននិយាយពីមាសត្រូវនោះលើសពីអ្វីដែលត្រូវនិយាយឡើយ ហើយខ្ញុំក៏មិនចូលចិត្តលើកឡើងពីវាដែរ តែបទពិសោធន៍នៃក្មេងប្រុសយ៉ូសែប បានរំឭកយើងពីអ្វីដែលមនុស្សគ្រប់រូប រួមទាំងគ្រប់យុវជនក្នុងចំណោមពួកអ្នកស្ដាប់នេះ ត្រូវចងចាំផងដែរ ។

ទីមួយ សាតាំង ឬលូស៊ីហ្វើរ ឬបិតានៃសេចក្ដីកុហក ----មិនថាអ្នកហៅវាបែបណាទេ ---វាគឺជាតួយ៉ាងដ៏ពិតនៃអំពើអាក្រក់ ។ គោលបំណងរបស់វា គឺកោងកាច ហើយវាកន្ត្រាក់អន្ទ្រូន ដោយប្រែរូបរាងជាពន្លឺប្រោសលោះ បន្លំខ្លួនធ្វើជាការពិត។  ទីពីរ វាត្រូវបានបដិសេធដ៏អស់កល្បចំពោះក្ដីស្រឡាញ់នៃព្រះ ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និងកិច្ចការនៃសេចក្ដីសុខសាន្ត និងការសង្គ្រោះ ។ វានឹងទាស់ប្រឆាំងនឹងការណ៍ទាំងនេះ នៅគ្រប់ពេល និងគ្រប់ទីកន្លែងដែលវាអាចធ្វើបាន ។ វាដឹងថា វានឹងត្រូវបរាជ័យ ហើយបណ្ដេញចេញនៅចុងបញ្ចប់ តែវាបានតាំងចិត្តនឹងនាំមនុស្សទៅជាមួយវាឲ្យបានច្រើនតាមដែលវាអាចធ្វើបាន ។

ចុះតើកលល្បិចមួយចំនួនរបស់អារក្សមានអ្វីខ្លះទៅក្នុងចម្បាំងនេះ ពេលជីវិតអស់កល្ប ស្ថិតនៅក្នុងគោលដៅរបស់វា ? ជាថ្មីទៀតបទពិសោធន៍ក្នុងព្រៃពិសិដ្ឋ គឺរឿងដ៏មានអត្ថប្រយោជន៍ ។ យ៉ូសែបបានកត់ត្រាថា ក្នុងកិច្ចខិតខំមួយដើម្បីបដិសេធរាល់ព្រឹត្តិការណ៍នាពេលអនាគត លូស៊ីហ្វើរ បានអនុវត្ត « ឥទ្ធិពលមកលើរូបខ្ញុំយ៉ាងអស្ចារ្យ ដែលចងអណ្ដាតខ្ញុំទុក ធ្វើឲ្យខ្ញុំមិនអាចនិយាយបានឡើយ » ។ [1]

សាតាំងមិនសម្លាប់មនុស្សម្នាក់ដោយផ្ទាល់បានឡើយ ។ នោះជារឿងមួយក្នុងចំណោមរឿងជាច្រើនដែលវាមិនអាចធ្វើបាន ។ តែបើតាមពិតទៅ ការខិតខំរបស់វា ដើម្បីបញ្ឈប់កិច្ចការនោះនឹងទទួលបានជោគជ័យ បើវាអាចចងអណ្ដាតមនុស្សស្មោះត្រង់ មិនឲ្យនិយាយ ។ បងប្អូនប្រុស បើដូច្នោះមែន នារាត្រីនេះ ខ្ញុំកំពុងតែសម្លឹងទៅបុរសទាំងក្មេងទាំងចាស់ ដែលមានការខ្វល់ខ្វាយពីចម្បាំងនេះរវាងអំពើល្អ និងអំពើអាក្រក់ ដើម្បីចូលរួម ហើយបន្លឺសម្លេងឡើង ។ យើងស្ថិតក្នុងសង្គ្រាម ហើយប៉ុន្មាននាទីទៀតនេះ ខ្ញុំចង់រើសមនុស្សដើម្បីចូលរួមក្នុងចម្បាំងនោះ ។

ខ្ញុំត្រូវការសំឡេងរហឹមៗនូវចង្វាក់មួយចំនួនថា « យើងទាំងអស់គ្នាត្រូវបានរើសឲ្យធ្វើជាទ័ព » បានទេ ? អ្នកដឹងឃ្លាអំពី « យើងកំពុងរង់ចាំទ័ពនៅពេលនេះ តើនរណានឹងស្ម័គ្រចិត្ត ? » [2] ពិតណាស់ រឿងដ៏អស្ចារ្យពីការហៅឲ្យបម្រើទ័ពនេះគឺថា យើងមិនមែន សុំអ្នកស្ម័គ្រចិត្តឲ្យទៅបាញ់កាំភ្លើង ឬបោះគ្រាប់បែកដៃនោះទេ ។ យើងចង់ឲ្យពួកអ្នកធ្វើចម្បាំងយក « គ្រប់ទាំងព្រះបន្ទូលដែលចេញពីព្រះឱស្ឋព្រះមក »ធ្វើជាអាវុធរបស់ពួកគេ ។ [3] ដូច្នេះនារាត្រីនេះ ខ្ញុំកំពុងស្វែងរកពួកអ្នកផ្សាយសាសនា ដែលនឹងមិនចងអណ្ដាតខ្លួនដោយចេតនានោះឡើយ តែនឹងបើកមាត់របស់ខ្លួន ហើយនិយាយនូវរឿងអព្ភូតហេតុ ដោយវិញ្ញាណនៃព្រះអម្ចាស់ និងអំណាចនៃបព្វជិតភាពរបស់ពួកគេ ។ មានពេលមួយ បងប្អូនប្រុសកាលពីមុន បាននិយាយថា ការនិយាយបែបនេះនឹងក្លាយជាមធ្យោបាយដែល « កិច្ចការដ៏អស្ចារ្យបំផុតនៃសេចក្ដីជំនឿត្រូវមាន និងត្រូវបានអនុវត្ត » ។ [4]

ជាពិសេសខ្ញុំសុំឲ្យយុវជននៃបព្វជិតភាពអើរ៉ុន អង្គុយឲ្យត្រង់ខ្លួន ហើយធ្វើការកត់ចំណាំទុក ។ ចំពោះអ្នក សូមឲ្យខ្ញុំលើកការប្រៀបធៀបមួយទាក់ទងនឹងកីឡា ។ នេះជាចម្បាំងដ៏ស្លាប់រស់មួយ ដែលយើងច្បាំង នឹងមាសត្រូវមួយដែលស្អប់អ្នក និងស្អប់កិច្ចការនេះ ដូច្នេះខ្ញុំនឹងឈរឲ្យជិតអ្នករាល់គ្នាដោយដាក់ច្រមុះទល់នឹងច្រមុះ ដោយនិយាយជាមួយនឹងអារម្មណ៍មួយនៃភាពបន្ទាន់ ---ជាវិធីដែលគ្រូបង្វឹកជាច្រើនធ្វើ ពេលការប្រកួតជិតមកដល់ ការមានជ័យជំនះគឺជារឿងមួយដ៏សំខាន់បំផុត ។ ហើយដោយសារការប្រកួតនេះពឹងផ្អែកទៅលើអ្នក អ្វីដែលគ្រូបង្វឹករូបនេះចង់ប្រាប់អ្នកគឺថា ដើម្បីលេងក្នុងការប្រកួតនេះ អ្នករាល់គ្នាមួយចំនួនត្រូវតែមានភាពស្អាតស្អំខាងសីលធម៌បន្ថែមទៀត ។ នៅក្នុងចម្បាំងរវាងអំពើល្អ និងអំពើអាក្រក់នេះ អ្នកមិនអាចលេងឲ្យខាងមាសត្រូវ នៅពេលណាកើតមានការល្បួង រួចហើយរំពឹងទុកឲ្យព្រះអង្គសង្គ្រោះពេញព្រះទ័យនៅឯព្រះវិហារបរិសុទ្ធ និងក្នុងបេសកកម្ម ធ្វើដូចជាគ្មានរឿងអ្វីកើតឡើងសោះបានឡើយ ។ មិត្តវ័យក្មេងរបស់ខ្ញុំ អ្នកមិនអាចធ្វើបែបនោះបានឡើយ ។ ព្រះនឹងមិនទ្រាំឲ្យចំអកឡើយ ។

ដូច្នេះយើងមានស្ថានភាពដ៏លំបាកមួយ ។ មានយុវជនក្នុងបព្វជិតភាពអើរ៉ុនរាប់ពាន់នាក់ដែលមានឈ្មោះលើកំណត់ហេតុក្នុងសាសនាចក្រនេះរួចហើយ ដែលអាចក្លាយជាពួកអ្នកផ្សាយសាសនានាពេលអនាគត ។ តែការលំបាកនោះ គឺការធ្វើឲ្យពួកឌីកុន ពួកគ្រូ និងពួកសង្ឃទាំងនោះបន្តសកម្ម និងមានភាពសក្តិសមល្មមគ្រប់គ្រាន់ ដើម្បីត្រូវបានតែងតាំងជាអែលឌើរ ហើយបម្រើជាពួកអ្នកផ្សាយសាសនា ។ ដូច្នេះ យើងត្រូវការយុវជនដែលនៅក្នុងក្រុមនេះរួចហើយ ឲ្យបន្ត នៅក្នុងក្រុមនេះ ហើយឈប់ធ្វើកំហុសធំៗ ពេលយើងត្រូវការអ្នកឲ្យចូលប្រកួត ហើយលេងឲ្យអស់ពីលទ្ធភាពអ្នក ! ក្នុងការប្រកួតអត្តពលកម្មភាគច្រើនដែលខ្ញុំដឹង មានបន្ទាត់មួយដែលត្រូវបានគេគូសនៅលើទីលាន ដើម្បីឲ្យកីឡាករគ្រប់រូបត្រូវតែស្ថិតនៅក្នុងនោះ ដើម្បីធ្វើការប្រកួត ។ មែនហើយ ព្រះអម្ចាស់បានគូសបន្ទាត់នៃភាពសក្តិសមសម្រាប់អស់អ្នកដែលត្រូវបានហៅឲ្យធ្វើការជាមួយទ្រង់ក្នុងកិច្ចការនេះ ។ គ្មានអ្នកផ្សាយសាសនាណាម្នាក់អាចសំណូមពរឲ្យមនុស្សដទៃប្រែចិត្តពីអំពើរំលងខាងផ្លូវភេទ ឬពាក្យសម្តីប្រមាថ ឬការបណ្តោយខ្លួនក្នុងរូបភាពអាសគ្រាម ទាំងខ្លួនឯងមិនបានធ្វើតាមនោះទេ ! អ្នកមិនអាចធ្វើវាបានឡើយ ។ ព្រះវិញ្ញាណនឹងមិនគង់ជាមួយអ្នកឡើយ ហើយពាក្យសម្តីទាំងឡាយនឹងស្អិតនៅក្នុងបំពង់កអ្នក ពេលអ្នកនិយាយ ។ អ្នកមិនអាចដើរចូលទៅក្នុងអ្វីដែលលីហៃហៅថា « ផ្លូវហាមឃាត់ទាំងឡាយ »[5] ហើយគិតចង់ដឹកនាំអ្នកដទៃទៅកាន់ « ផ្លូវត្រង់ ហើយចង្អៀត »[6] នោះ ---គឺវាមិនអាចកើតឡើងបានឡើយ ។

តែមានវិធីមួយដើម្បីអ្នកអាចយកឈ្នះអំពើបាបអ្នក ហើយក៏មានវិធីមួយដូចគ្នាសម្រាប់អ្នករៀនដែលអ្នកនឹងបង្រៀនឲ្យឈ្នះពីអំពើបាបពួកគេផងដែរ ។ ទោះអ្នកជានរណា និងអ្វីដែលអ្នកធ្លាប់ធ្វើក្តី អ្នកអាចទទួលការអភ័យទោសបាន ។ អ្នករាល់គ្នាគ្រប់រូបអាចជម្រុះចោលនូវអំពើរំលងនានាដែលអ្នកកំពុងឆ្លងកាត់ ។ វាជា « អព្ភូតហេតុនៃការអភ័យទោស » ជាអព្ភូតហេតុនៃដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ តែអ្នកមិនអាចធ្វើវាដោយគ្មានការតាំងចិត្តដ៏មុតមាំចំពោះដំណឹងល្អបានឡើយ ហើយអ្នកមិនអាចធ្វើវាដោយគ្មានការប្រែចិត្តដ៏ចាំបាច់បានឡើយ ។ យុវជនទាំងឡាយ ខ្ញុំកំពុងសុំឲ្យអ្នកធ្វើជាសមាជិកសកម្ម ហើយស្អាតស្អំ ។ បើត្រូវធ្វើ ខ្ញុំនឹងសុំអ្នក *ឲ្យ* សកម្ម ហើយ *ឲ្យ* ស្អាតស្អំ ។

បងប្អូនប្រុស យើងនិយាយពាក្យម៉ឺងម៉ាត់ចំពោះអ្នក ដោយសារការនិយាយលួងលោមហាក់ដូចជាពុំសូវមានឥទ្ធិពលលើអ្នកសោះ ។ យើងនិយាយដោយម៉ឺងម៉ាត់ដោយសារសាតាំងគឺមានពិតមែន ហើយវាតាំងចិត្តដើម្បីបំផ្លាញអ្នក ហើយអ្នកជួបឥទ្ធិពលរបស់វានៅក្នុងភាពយុវវ័យ ។ ដូច្នេះ យើងក៏ចាប់ក្រប៉ូចកអាវអ្នក ហើយស្រែកខ្លាំងៗតាមដែលយើងអាចធ្វើបានថា ៖

សូមស្តាប់ ! សម្លេងនៃចម្បាំងកំពុងបន្លឺឡើងយ៉ាងលាន់រំពង ហើយច្បាស់សូមមកចូលរួមនឹងពលទ័ពនេះ ! សូមមកចូលរួមនឹងពលទ័ពនេះ![7]មិត្តវ័យក្មេងរបស់ខ្ញុំ យើងត្រូវការពួកអ្នកផ្សាយសាសនារាប់ពាន់រាប់ម៉ឺននាក់បន្ថែមទៀតនៅក្នុងខែ និងឆ្នាំខាងមុខ ។ ពួកគេត្រូវតែកើតចេញពីចំនួនដ៏ច្រើននៃបព្វជិតភាពអើរ៉ុន ដែលត្រូវបានតែងតាំង សកម្ម ស្អាតស្អំ និងសក្តិសមដើម្បីបម្រើ ។

ចំពោះអ្នកដែលធ្លាប់បានបម្រើបេសកកម្ម ឬក៏កំពុងបម្រើនាពេលនេះ យើងសូមអរគុណអ្នកសម្រាប់ការល្អដែលអ្នកបានធ្វើ និងសម្រាប់មនុស្សដែលអ្នកបានជួយ ។ សូមឲ្យអ្នកបានពរចុះ ! យើងក៏សូមទទួលស្គាល់ថា មានមនុស្សមួយចំនួនដែលធ្លាប់សង្ឃឹមក្នុងជីវិតរបស់ខ្លួនដើម្បីបម្រើបេសកកម្ម តែដោយសារហេតុផលខាងសុខភាព ឬឧបសគ្គផ្សេងទៀតដែលហួសពីការគ្រប់គ្រងរបស់ខ្លួន ទើបមិនអាចធ្វើកិច្ចការនេះបាន ។ យើងសូមកោតសរសើរជាសាធារណៈ និងដោយមោទនភាពចំពោះក្រុមនេះ ។ យើងដឹងពីក្តីប្រាថ្នាអ្នក យើងសរសើរចំពោះការលះបង់អ្នក ។ អ្នកមានក្តីស្រឡាញ់ និងក្តីកោតសរសើររបស់យើង ។ អ្នកស្ថិតនៅក្នុង « ក្រុមនេះ » ហើយនិងស្ថិតនៅជារៀងរហូត ទោះជាអ្នកត្រូវបានសុំឲ្យដកខ្លួនដោយកិត្តិយសពីការបម្រើពេញម៉ោងនេះក្តី ។ តែយើងត្រូវការអ្នកដែលនៅសេសសល់ !

ឥឡូវនេះ អ្នកដែលជាបងប្អូនប្រុសនៃបព្វជិតភាពមិលគីស្សាដែក ។ សូមកុំទាន់ញញឹម ហើយអង្គុយផ្អែកខ្នងដោយស្រួលក្នុងកៅអីរបស់ខ្លួនឡើយ ។ ខ្ញុំមិនទាន់និយាយចប់នៅឡើយទេ ។ យើងត្រូវការស្វាមីភរិយារាប់ពាន់នាក់បន្ថែមទៀត ដើម្បីបម្រើបេសកកម្មក្នុងសាសនាចក្រ ។ គ្រប់ប្រធានបេសកកម្មសុំអង្វរឲ្យមានពួកគេ ។ នៅគ្រប់ទីកន្លែងដែលពួកគេបម្រើ គូស្វាមីភរិយារបស់យើងបាននាំយកនូវភាពចាស់ទុំទៅក្នុងកិច្ចការនេះ ដែលគ្មានក្មេងអាយុ 19 ឆ្នាំណាម្នាក់ អាចផ្តល់ឲ្យឡើយ ទោះជាពួកគេពូកែប៉ុណ្ណាក្តី ។

ដើម្បីលើកទឹកចិត្តឲ្យមានគូស្វាមីភរិយាបន្ថែមទៀតធ្វើកិច្ចការបម្រើ នោះគណៈប្រធានទីមួយ និងកូរ៉ុមនៃពួកដប់ពីរនាក់បានធ្វើនូវការផ្លាស់ប្តូរមួយដ៏ម៉ឺងម៉ាត់ ហើយសប្បុរសបំផុតនៅក្នុងកិច្ចការផ្សាយសាសនាក្នុង រយៈពេល 50 ឆ្នាំនេះ ។ ក្នុងខែ ឆ្នាំនេះពួកអ្នកដឹកនាំបព្វជិតភាពក្នុងតំបន់បានទទួលសេចក្តីជូនដំណឹងមួយថា ថ្លៃផ្ទះរបស់គូស្វាមីភរិយា ( ហើយយើងនិយាយតែចំពោះថ្លៃផ្ទះប៉ុណ្ណោះ) នឹងត្រូវបានបំពេញបង្គ្រប់ដោយមូលនិធិផ្សាយសាសនារបស់សាសនាចក្រ បើថ្លៃនោះលើសពីថ្លៃដែលបានរៀបចំជាមុនក្នុងមួយខែ ។ វាជាពរជ័យអ្វីម្ល៉េះ ! នេះជាជំនួយដែលបានបញ្ជូនមកពីស្ថានសួគ៌ចំពោះចំណាយដ៏ធំបំផុតមួយដែលគូស្វាមីភរិយារបស់យើងជួបប្រទះក្នុងបេសកកម្ម ។ បងប្អូនប្រុសក៏បានកំណត់ផងដែរថា បេសកកម្មជាគូស្វាមីភរិយា អាចធ្វើឡើងរយៈពេល 6 ឬ 12 ខែ ឬអាចធ្វើតាមទម្លាប់គឺ 18 ឬ 24 ខែ ។ ក្នុងការបង្ហាញឲ្យឃើញមួយទៀត ការអនុញ្ញាតត្រូវបានផ្តល់ដល់គូ

ស្វាមីភរិយាក្នុងការចំណាយរបស់ ខ្លួន ដើម្បីត្រឡប់ទៅផ្ទះក្នុងរយៈពេលខ្លីសម្រាប់ព្រឹត្តិការណ៍សំខាន់ក្នុងគ្រួសារ ។ ហើយកុំបារម្ភថា អ្នកនឹងត្រូវដើរគោះទ្វា ឬមានកាលវិភាគដូចគ្នានឹងពួកក្មេង 19 ឆ្នាំឡើយ ! យើងមិនសុំឲ្យអ្នកធ្វើដូច្នោះឡើយ  តែសុំអ្នកឲ្យធ្វើរឿងផ្សេងទៀតដែលអ្នកអាចធ្វើបាន ហើយមានសេរីភាពពេញលេញក្នុងការសម្រេចចិត្តពីរបៀបដែលអ្នកនឹងធ្វើ ។

បងប្អូនប្រុស យើងដឹងថា អ្នករាល់គ្នាមួយចំនួនមិនអាចចេញបេសកកម្មនៅពេលនេះបានឡើយ ដោយសារបញ្ហាសុខភាព គ្រួសារ និងសេដ្ឋកិច្ច ។ តែដោយមានការរៀបចំផែនការបន្តិចបន្តួច នោះអ្នករាល់គ្នាភាគច្រើនអាចធ្វើបាន ។ ប៊ីស្សព និងប្រធានស្តេក សូមពិភាក្សាពីសេចក្តីត្រូវការនេះក្នុងក្រុមប្រឹក្សា និងសន្និសីទរបស់អ្នក ។ សូមអង្គុយនៅលើវេទិកា ក្នុងការប្រជុំអ្នក ហើយសម្លឹងមើលទៅក្រុមជំនុំប្រកបដោយការអធិស្ឋានសម្រាប់ការបំផុសគំនិតពីអ្នកដែលគួរទទួលការហៅមួយ ។ រួចហើយសូមប្រឹក្សាជាមួយពួកគេ ហើយជួយពួកគេដាក់កាលបរិច្ឆេទមួយសម្រាប់ការបម្រើនេះ ។ បងប្អូនប្រុស ពេលការណ៍នោះកើតឡើង សូមប្រាប់ភរិយាអ្នកថា បើអ្នកអាចចាកចេញពីកៅអីដ៏ទន់ និងប្រដាប់បញ្ជាសម្រាប់រយៈពេលប៉ុន្មានខែ តើភរិយាពួកគេអាចចាកចេញពីចៅៗបានទេ ។ ក្មេងតូចៗទាំងនោះនឹងមិនមានបញ្ហាអ្វីឡើយ ហើយខ្ញុំសូមសន្យាថា អ្នកនឹងធ្វើរឿងទាំងនោះសម្រាប់ពួកគេក្នុងការបម្រើព្រះអម្ចាស់ ដែលអ្នកនឹងមិនអាចធ្វើបានឡើយ បើអ្នកនៅតែក្នុងផ្ទះចំណាយពេលច្រើននឹងពួកគេនោះ ។ ជីដូនជីតាទាំងឡាយ មិនអាចឲ្យអំណោយមួយដ៏ធំដល់កូនចៅរបស់ពួកគេជាងការប្រព្រឹត្ត ក៏ដូចជាពាក្យសម្តីថា « ក្នុងគ្រួសារនេះ យើងបម្រើបេសកកម្ម ! » ។

កិច្ចការផ្សាយសាសនាមិនមែនជារឿងតែមួយដែលយើងត្រូវធ្វើក្នុងសាសនាចក្រដ៏អស្ចារ្យ ហើយធំនេះឡើយ ។ តែស្ទើរតែរឿងគ្រប់យ៉ាងផ្សេងទៀតដែលយើងត្រូវធ្វើ ផ្អែកលើមនុស្ស ឮដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយចូលរួមក្នុងសាសនាយើង ជាមុនសិន ។ ពិតណាស់ នោះជាហេតុផលដែលបញ្ញាចុងក្រោយរបស់ព្រះយេស៊ូវមានចំពោះពួកដប់ពីរនាក់មានភាពសាមញ្ញ ---គឺ « ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ សាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាម ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ » ។ [8] ហើយមានតែធ្វើដូច្នេះប៉ុណ្ណោះ ទើបពរជ័យនៃដំណឹងល្អអាចកើតមាន ដូចជា --- សាមគ្គីភាពក្នុងគ្រួសារ កម្មវិធីយុវវ័យ ការសន្យានៃបព្វជិតភាព និងពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធ ។ តែដូចដែលនីហ្វៃបានថ្លែងទីបន្ទាល់ គ្មានការណ៍ណាមួយអាចកើតឡើងបានឡើយ រហូតមនុស្សម្នាក់បាន « ចូលតាមទ្វារ ...នោះ » ។ [9] ដោយសារមានរឿងជាច្រើនដែលត្រូវធ្វើនៅតាមផ្លូវទៅកាន់ជីវិតអស់កល្ប យើងត្រូវការពួកអ្នកផ្សាយសាសនាច្រើនបន្ថែមទៀត ដើម្បីបើកទ្វារនោះ ហើយជួយមនុស្សដទៃឲ្យឆ្លងកាត់ទ្វារនោះ ។

ខ្ញុំសុំឲ្យបុរសទាំងអស់ ទាំងចាស់ទាំងក្មេងដែលកាន់បព្វជិតភាព ឲ្យមានភាពរឹងមាំ និងមានការលះបង់បន្ថែមទៀតក្នុងការថ្លែងទីបន្ទាល់ ជាសំឡេងមួយដែលមិនមែនតតាំង តែនឹងអំពើអាក្រក់ និងអារក្សដែលជាតួយ៉ាងនៃអំពើអាក្រក់ប៉ុណ្ណោះទេ ។ បងប្អូនប្រុសក្នុងគ្រប់វ័យទាំងអស់ ចូរបើកមាត់របស់អ្នក ហើយមើលពាក្យសម្តីអ្នកធ្វើការដ៏អស្ចារ្យក្នុងជីវិតនៃអស់អ្នកដែល « លាក់ពីសេចក្តីពិត ពីព្រោះពួកគេមិនដឹងទៅរកសេចក្តីពិតឯណាទេ » ។ [10] ចូរប្រញាប់ចូលក្នុងទីចម្បាំង និងសមរភូមិ សេចក្តីពិតធ្វើជា មួកការពារ និងខែលយើង ។ ឈរក្បែរទង់យើង ដែលកំពុងបក់ដោយមោទនភាព ! យើងកំពុងដើរជាក្បួនដោយមានអំណរជាខ្លាំងទៅផ្ទះរបស់យើង ។ [11] ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទជាចៅហ្វាយយើង អាម៉ែន ។

កំណាត់ចំណាំ

1. យ៉ូសែប ស៊្មីធ---ប្រវត្តិ 1:15 ។
2. « We Are All Enlisted » *Hymns,* no. 250 ។
3. គោលលទ្ធិ និងសេចក្តីសញ្ញា 84:44, សូមមើលផងដែរ ចោទិយកថា 8:3, ម៉ាថាយ 4:4 ។
4. *Lectures on Faith* (1985) ទំព័រ 74 ។
5. នីហ្វៃទី1 8:28 ។
6. នីហ្វៃទី *2* 31:18 ។
7. *Hymns,* no. 250 ។
8. ម៉ាថាយ 28:19 ។
9. នីហ្វៃទី2  33:9 ។
10. គោលលទ្ធិ និងសេចក្តីសញ្ញា 123:12 ។
11. *Hymns,* no. 250 ។